# យុទ្ធសាស្ត្រ និង ផែនការសកម្មភាពបរិស្ថានជាតិរបស់កម្ពុជា

## កម្មវិធីសិក្ខាសាលាចាប់ផ្តើមគម្រោង

## ឯកសារទស្សនៈទាន

**ថ្ងៃច័ន្ទ ទី ០២ ខែ វិច្ឆិកា ឆ្នាំ ២០១៥**
**នៅ សណ្ឋាគារ អ៊ីនធើខនធីណិនថល**

រាជរដ្ឋាភិបាលកម្ពុជា យកចិត្តទុកដាក់លើចីរភាពភាពបរិស្ថាន ដោយមានចែងនៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ ជាលក្ខខណ្ឌចម្បង ក្នុងការឈានទៅសម្រេចគោលដៅនយោបាយអភិវឌ្ឍន៍សង្គម និង សេដ្ឋកិច្ចជាតិ[1]។ ការបង្កើតនូវក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាពនាថ្ងៃទី២០ ខែឧសភាឆ្នាំ២០១៥ បង្ហាញពីជំហរនៃរាជរដ្ឋាភិបាលកម្ពុជាក្នុងការប្តេជ្ញាចិត្តបញ្ជ្រាបនូវបញ្ហាបរិស្ថាន ការប្រែប្រួលអាកាសធាតុ ការកាត់បន្ថយហានិយភ័យមហន្តរាយ និង បញ្ហាសង្គមក្នុងក្របខ័ណ្ឌអភិវឌ្ឍន៍ប្រទេស។

ការរៀបចំបង្កើតយុទ្ធសាស្ត្រ និង ផែនការសកម្មភាពបរិស្ថានជាតិគឺ តម្រូវដោយច្បាប់ស្តីពីកិច្ចគាំពារបរិស្ថាន និង ការគ្រប់គ្រងធនធានធម្មជាតិ ឆ្នាំ១៩៩៦[2] ដែលមានគោលបំណងផ្តល់នូវផែនទីបង្ហាញផ្លូវមួយសម្រាប់ការរៀបចំធ្វើផែនការបរិស្ថាន និង ធនធានធម្មជាតិ ដើម្បីធានាប្រសិទ្ធិភាព នៃកិច្ចគាំពារបរិស្ថាន និង ការប្រើប្រាស់ធនធានធម្មជាតិ ប្រកបដោយចីរភាព តាមរយៈដំណើរការចូលរួម និង ការផ្តល់យោបល់។ យុទ្ធសាស្ត្រ និង ផែនការសកម្មភាពបរិស្ថានជាតិមិនមែនជាយុទ្ធសាស្ត្រផ្តោតចំពោះតែក្រសួងបរិស្ថាននោះទេ តែវាគឺជាយុទ្ធសា

---

[1] RSIII, កថាខ័ណ្ឌ១៩ ទំព័រទី១០[http://www.cambodiainvestment.gov.kh/content/uploads/2013/11/2013-Rectangular-Strategy-III-En8.pdf](http://www.cambodiainvestment.gov.kh/content/uploads/2013/11/2013-Rectangular-Strategy-III-En8.pdf)

[2] កិច្ចគាំពារបរិស្ថាន និង ការគ្រប់គ្រងធនធានធម្មជាតិ ឆ្នាំ១៩៩៦ ត្រូវបានអនុម័តនៅថ្ងៃ ទី ១៨ ខែ វិច្ឆិកាឆ្នាំ១៩៩៦។មាត្រាទី២ កំណត់ការបង្កើតផែនការបរិស្ថានជាតិមួយនិងផែនការបរិស្ថានថ្នាក់តំបន់មួយចំនួន ជាកិច្ចឆ្លើយតបនឹង សំណើររបស់ក្រសួងបរិស្ថានជាមួយក្រសួងពាក់ព័ន្ធ ។មាត្រាទី៣និង៤មានកំណត់បន្ថែមថាផែនការបរិស្ថានជាតិមួយនិងផែនការបរិស្ថានថ្នាក់តំបន់មួយចំនួនគឺជាផែនការសម្រាប់ ការពារបរិស្ថាននិងការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយចីរភាពសម្រាប់ទូទាំងប្រទេស។

ស្ត្រណែនាំរួមដល់ស្ថាប័នពាក់ព័ន្ធទាំងអស់ រួមមាន៖ ស្ថាប័នរដ្ឋ វិស័យកជន សង្គមស៊ីវិល និង ដៃគូអភិវឌ្ឍន៍ ក្នុងកិច្ចប្រឹងប្រែងបញ្ជ្រាបបញ្ហាបរិស្ថានទៅក្នុងកម្មវិធីវិនិយោគ និង នយោបាយអភិវឌ្ឍន៍សេដ្ឋកិច្ច នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ យុទ្ធសាស្ត្រ និង ផែនការសកម្មភាពបរិស្ថានជាតិ គ្របដណ្តប់ ឆ្នាំ២០១៦ ដល់ ២០២៣ ដែលដើរស្របជាមួយយុទ្ធសាស្ត្រចតុកោណ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និង វដ្តនៃការធ្វើផែនការជាតិដទៃទៀត។ដំណើរការ រៀបចំបង្កើតយុទ្ធសាស្ត្រ និង ផែនការសកម្មភាពបរិស្ថានជាតិ បានចាប់ផ្តើមនៅខែកញ្ញា ឆ្នាំ២០១៥ ហើយឯកសារចុងក្រោយនឹងត្រូវត្រួតពិនិត្យ ដោយក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាពមុនដាក់ជូនរាជរដ្ឋាភិបាលពិនិត្យ និង អនុម័តជាផ្លូវការ មុនដំណាច់ឆ្នាំ២០១៦។ សម្រាប់ព័ត៌មានលម្អិតស្តីពី យុទ្ធសាស្ត្រ និង ផែនការសកម្មភាពបរិស្ថាន ជាតិ សូមអានសេចក្តីបន្ថែមទី១ខាងក្រោម។

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បាន អនុញ្ញាត ជាគោលការណ៍ដូចខាងក្រោម៖

ទី១ ឱ្យក្រសួងបរិស្ថានដឹកនាំការរៀបចំកសាង "យុទ្ធសាស្ត្រ និងផែនការសកម្មភាពបរិស្ថានជាតិ"

ទី២ ឱ្យប្រើប្រាស់ "ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព" ជា យន្តការសម្រាប់ត្រួតពិនិត្យ និងឆ្លងសេចក្តីព្រាង "យុទ្ធសាស្ត្រ និង ផែនការសកម្មភាពបរិស្ថានជាតិ" មុនដាក់ជូនរាជរដ្ឋាភិបាលពិនិត្យនិងអនុម័តជាផ្លូវការ។

ទី៣ ឱ្យក្រសួងបរិស្ថានបង្កើត "ក្រុមការងារចំពោះកិច្ច" មួយចំនួនតាមការចាំបាច់ ដែលមានសមាសភាពអន្តរក្រសួង ដើម្បីសម្របសម្រួល និងដឹកនាំកម្រិតបច្ចេកទេស សម្រាប់ការរៀបចំកសាង "យុទ្ធសាស្ត្រ និងផែនការសកម្មភាពបរិស្ថានជាតិ"។ ក្រុមការងារចំពោះកិច្ចទាំងនេះ ត្រូវសហការ ជាមួយទីប្រឹក្សាជាតិនិងអន្តរជាតិនានា និងអ្នកជំនាញមកពីអង្គការ និងស្ថាប័នពាក់ព័ន្ធសំខាន់ៗ ដើម្បីរៀបចំសេចក្តីព្រាងយុទ្ធសាស្ត្រ និងផែនការសកម្មភាពបរិស្ថាន ទៅតាមផ្នែករៀងៗខ្លួន (ទីស្តីការគណៈ រដ្ឋមន្ត្រី លេខ១០៦៩ សជណ.កស ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៥)។

ការរៀបចំក្រមបរិស្ថានជាតិ ដើរស្របគ្នានឹងកសាងយុទ្ធសាស្ត្រ និង ផែនការសកម្មភាពបរិស្ថានជាតិជានានូវបង្កើតគោលការណ៍ និង ក្របខ័ណ្ឌច្បាប់រួមមួយ ឆ្ពោះទៅសម្រេចគោលដៅគ្រប់គ្រង និង អភិវឌ្ឍន៍ធនធានធម្មជាតិប្រកបដោយចីរភាពក្នុងព្រះរាជាណាចក្រកម្ពុជា។ ជាមួយនឹងភាពបំពេញបន្ថែមគ្នា ក្រមបរិស្ថានផ្តោតជាចម្បងលើទិដ្ឋភាពច្បាប់គ្រប់គ្រងបរិស្ថាន និងធនធានធម្មជាតិ ចំណែកឯយុទ្ធសាស្ត្រ និងផែនការសកម្មភាពបរិស្ថានជាតិវិញគឺផ្តោតទៅលើបញ្ហាគោលនយោបាយ និងហិរញ្ញវត្ថុ។ បញ្ហាសំខាន់ៗជាច្រើននឹងត្រូវលើកយកមកពិនិត្យ និងវិភាគក្នុងដំណើរការរៀបចំកសាងឯកសារទាំងពីរនេះ។

ការរៀបចំកសាងយុទ្ធសាស្ត្រ និងផែនការសកម្មភាពបរិស្ថានជាតិ បានទទួលនូវការគាំទ្រពីកម្មវិធីបរិស្ថានស្នូលមហាអនុតំបន់មេគង្គ (CEP)នៃ ធនាគារអភិវឌ្ឍន៍អាស៊ី។ ក្រសួងបរិស្ថាន និងក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាពនឹងដឹកនាំដំណើរការពិគ្រោះយោបល់ជាមួយស្ថាប័នរដ្ឋ នៅក្នុងដំណើរការរៀបចំ។

## កម្មវត្ថុ និង ការរៀបចំសិក្ខាសាលា

សិក្ខាសាលានេះរៀបចំឡើងដោយក្រសួងបរិស្ថាន និងមជ្ឈមណ្ឌលប្រតិបត្តិការបរិស្ថាន (EOC)នៃមហាអនុតំបន់មេគង្គរបស់ធនាគារអភិវឌ្ឍន៏អាស៊ី ដើម្បីជូនដំណឹង និងស្វែងរកកិច្ចសហប្រតិបត្តិការ ការចូលរួម និងការមូលមតិគ្នា ក្នុងចំណោមអ្នកពាក់ព័ន្ធក្នុងការរៀបចំកសាងយុទ្ធសាស្រ្ត និងផែនការសកម្មភាពបរិស្ថានជាតិ។ សកម្មភាពការងារ និង លទ្ធផលរំពឹងទុកចំបងៗ ពីសិក្ខាសាលានេះ សង្ខេបជូនក្នុងតារាងទី១ខាងក្រោម៖

**តារាងទី១** សកម្មភាពការងារ និង លទ្ធផលរំពឹងទុកចំបងៗពីសិក្ខាសាលា

| **សកម្មភាពការងារ** | **លទ្ធផលរំពឹងទុក** |
|---|---|
| 1. បង្ហាញអំពីទស្សនៈគម្រោងស្តីពីការរៀបចំបង្កើតយុទ្ធសាស្រ្ត និងផែនការសកម្មភាពបរិស្ថានជាតិ (កម្មវត្ថុ ដំណើរការ វិធីសាស្រ្ត និងបញ្ហាសំខាន់ៗ ដែលនឹងលើកឡើងក្នុងឯកសារ)<br>2. បង្ហាញ និងពិភាក្សាអំពីសក្តានុពលយុទ្ធសាស្រ្ត និងផែនការសកម្មភាពបរិស្ថានជាតិ ក្នុងការគាំទ្រដល់ការសម្រេចគោលដៅលើកឡើងក្នុងយុទ្ធសាស្រ្ត និងផែនការសេដ្ឋកិច្ច យុទ្ធសាស្រ្ត និងផែនការអភិវឌ្ឍន៍ និងតាមវិស័យ ក្នុងប្រទេសកម្ពុជា | • ទទួលបានមតិ និងការឯកភាពគ្នាលើ៖ ទី១ វិធីសាស្រ្តចូលរួម(ក្រុមការងារអន្តរក្រសួង)។ ទី២ វិធីសាស្រ្តរៀបចំបង្កើតយុទ្ធសាស្រ្ត និងផែនការសកម្មភាពបរិស្ថានជាតិ។ ទី៣ ចំណុចសំខាន់ៗ ដែលនឹងដាក់បញ្ចូលក្នុងឯកសារយុទ្ធសាស្រ្ត និងផែនការសកម្មភាពបរិស្ថានជាតិ។ ទី៤ ផែនការការងារ (ភារកិច្ច និងការទទួលខុសត្រូវរបស់អ្នកពាក់ព័ន្ធ) និងទី៥ បណ្តាញទំនាក់ទំនង។<br>• បានចែករំលែកការយល់ដឹងដល់អ្នកពាក់ព័ន្ធអំពី៖ កម្មវត្ថុរបស់យុទ្ធសាស្រ្ត និងផែនការសកម្មភាពបរិស្ថានជាតិ និងវិភាគទានដល់កម្មវិធីអភិវឌ្ឍន៍សង្គម និងសេដ្ឋកិច្ចជាតិ<br>• បានទទួលនូវការប្តេជ្ញាចិត្ត និងការគាំទ្រពីអ្នកពាក់ព័ន្ធក្នុងការចូលរួមរៀបចំបង្កើតយុទ្ធសាស្រ្ត និងផែនការសកម្មភាពបរិស្ថានជាតិ។ |
| 3. បង្ហាញ និងប្រមូលមតិយោបល់លើការសិក្សាស្រាវជ្រាវបឋមអំពី៖ ទី១ បរិស្ថាន សេដ្ឋកិច្ច និង សង្គម។ ទី២ ការវិភាគ និន្នាការ និង ស្ថានភាព នៃធនធានធម្មជាតិ និងបរិស្ថាន។ ទី៣ ការប្រមូលព័ត៌មានដែលមានស្រាប់ស្តីពី បណ្តាផែនការ នយោបាយ និង យុទ្ធសាស្រ្តពាក់ព័ន្ធនឹងបរិស្ថាន និង ការអភិវឌ្ឍន៍ដោយចីរភាព។ | ទទួលបានមតិយោបល់ទៅលើ៖ ទី១ ការសិក្សាស្រាវជ្រាវបឋម។ ទី២ ការឯកភាពលើការចូលរួមផ្តល់ព័ត៌មាន និង ទិន្នន័យពីអ្នកពាក់ព័ន្ធ និងទី៣ ការណែនាំលើប្រធានបទបន្ថែម ដែលនឹងដាក់បញ្ចូលក្នុងឯកសារយុទ្ធសាស្រ្ត និង ផែនការសកម្មភាពបរិស្ថានជាតិ។ |
| 4. បង្ហាញ និងពិភាក្សាអំពី៖ ការកំណត់ទស្សនៈវិស័យ ការធ្វើផែនការ និង ក្របខ័ណ្ឌការងារអាទិភាព របស់យុទ្ធសាស្រ្ត និង ផែនការសកម្មភាពបរិស្ថានជាតិ។ | ទទួលបាននូវមតិ និង ការព្រមព្រៀងគ្នាទៅលើ៖ ការកំណត់ទស្សនៈវិស័យ ការធ្វើផែនការ និង ក្របខ័ណ្ឌការងារអាទិភាព |

| | |
|---|---|
| 5. ដើម្បីពិភាក្សាជំហានបន្ទាប់រួមមាន៖ ទី១ ផែនការការងារ។ ទី២ ការចូលរួមរបស់អ្នកពាក់ព័ន្ធ និងការសម្របសម្រួល។ ទី៣ ការចែករំលែកទិន្នន័យ និងព័ត៌មាន។ និង ទី៤ យន្តការពិនិត្យ និងផ្តល់មតិទៅលើសេចក្តីព្រាង (ទិន្នន័យ និង ការវិភាគ)។ | ទទួលបាននូវការឯកភាពទៅលើវិធីសាស្រ្តជាក់ស្តែងដែលនឹងត្រូវអនុវត្តដើម្បី៖ ទី១ ពង្រឹងការសម្របសម្រួល ទី២ ចែករំលែក និង ផ្លាស់ប្តូរព័ត៌មានគ្នាអំពីបច្ចុប្បន្នភាព នៃវឌ្ឍនភាពក្នុងការរៀបចំបង្កើតយុទ្ធសាស្រ្ត និងផែនការសកម្មភាពបរិស្ថានជាតិ និង ទី៣ ពិនិត្យទិន្នន័យ ការវិភាគ សេចក្តីព្រាង និង យន្តការពិនិត្យ។ |

## របៀបវារៈ និង សិក្ខាកាម

សិក្ខាសាលានេះនឹងមានការចូលរួមពីតំណាងមកពី ក្រសួង-ស្ថាប័នរដ្ឋ ដៃគូអភិវឌ្ឍន៍ ស្ថាប័នសិក្សាស្រាវជ្រាវ អង្គការសង្គមស៊ីវិល និង វិស័យឯកជនចំនួន១០០នាក់។ ឯកសារ និង បទបង្ហាញនឹងត្រូវផ្តល់ជូនសិក្ខាកាម។ សេចក្តីសង្ខេបពិស្តារអំពី ចំណុចសំខាន់ៗដែលបានពិភាក្សាក្នុងអង្គសិក្ខាសាលា និងសកម្មភាពដែលត្រូវ អនុវត្តបន្តនឹងផ្តល់ជូនក្រោយពេលបញ្ចប់សិក្ខាសាលា។ តារាងទី២ខាងក្រោមបង្ហាញពីកម្មវិធីគ្រោង របស់សិក្ខាសាលា។

**តារាងទី២** កម្មវិធីគ្រោងរបស់សិក្ខាសាលា

| **ម៉ោង** | **ប្រធានបទ** | **វាគ្មិន** | **ប្រធានអង្គប្រជុំ** |
|---|---|---|---|
| ៧.៣០-៨.៣០ | ចុះឈ្មោះសិក្ខាកាម | | |
| **សម័យប្រជុំទី១៖ ពិធីបើក** | | | |
| ៨.៣០-៨.៤៥ | មតិស្វាគមន៍ និង សេចក្តីផ្តើមសិក្ខាសាលា | **ឯកឧត្តម សៅ សុភាព**<br>ទីប្រឹក្សាក្រសួងបរិស្ថាននិងប្រធានក្រុមការងារកិច្ចសហការ ការធ្វើផែនការ និង ការកំណត់ថវិកា | |
| ៨.៤៥-**៩**.០០ | ចំណាប់អារម្មណ៍ | Mr. Pavit Ramachandran<br>អ្នកឯកទេសជាន់ខ្ពស់ផ្នែកបរិស្ថាន នៃធនាគារអភិវឌ្ឍន៍អាស៊ី | |
| ៩.០០-៩.៣០ | មតិបើកសិក្ខាសាលា | **ឯកឧត្តម សាយ សំអាល់**<br>រដ្ឋមន្ត្រីក្រសួងបរិស្ថាននិងជាប្រធានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព | |
| ៩.៣០-៩.៥០ | ថតរូប និង សម្រាកពិសារកាហ្វេ | | |
| **សម័យប្រជុំទី២៖ កម្មវត្ថុ ដំណើរការ និង វិធីសាស្ត្ររៀបចំបង្កើតយុទ្ធសាស្ត្រ និង ផែនការសកម្មភាពបរិស្ថានជាតិ** | | | |
| ៩.៥០-១០.១០ | បទបង្ហាញស្តីពី កម្មវិធីបរិស្ថានស្នូល និងការគាំទ្រ នៃកម្មវិធីនេះ ដល់ការរៀបចំបង្កើតយុទ្ធសាស្ត្រ និងផែនការសកម្មភាពបរិស្ថានជាតិ និងកម្មវិធីបរិស្ថានដទៃទៀត ក្នុងប្រទេសកម្ពុជា | Mr. Iain Watson and Ms. Shannon Wang, EOC | **ឯកឧត្តម សៅ សុភាព**<br>ទីប្រឹក្សាក្រសួងបរិស្ថាន និងប្រធានក្រុមការងារកិច្ចសហការ ការធ្វើផែនការ និងការ |

| | | | |
|---|---|---|---|
| ១០.១០-១០.៤០ | បទបង្ហាញស្តីពី កម្មវត្ថុ ដំណើរការ និង វិធីសាស្ត្រ ព្រមទាំងបញ្ហាសំខាន់ៗ និង ផែនការការងារ រៀបចំបង្កើតយុទ្ធសាស្ត្រ និង ផែនការសកម្មភាពបរិស្ថានជាតិ | បណ្ឌិត Sokhem Pech ប្រធានក្រុមការងារគម្រោង និងជា អ្នកឯកទេសនយោបាយបរិស្ថានអន្តរជាតិ និងការធ្វើផែនការ | កំណត់ថវិកា |
| ១០.៤០-១២.២០ | សម្របសម្រួលកិច្ចពិភាក្សារួមដើម្បីះ<br>• ស្វែងរកការប្តេជ្ញាចិត្ត និងការគាំទ្រពីអ្នកពាក់ព័ន្ធក្នុងដំណើរការរៀបចំបង្កើតយុទ្ធសាស្ត្រ និងផែនការសកម្មភាពបរិស្ថានជាតិ។<br>• ការកំណត់ទស្សនៈវិស័យយុទ្ធសាស្ត្រ និងផែនការសកម្មភាពបរិស្ថានជាតិ<br>• ប្រមូលមតិយោបល់ និងការឯកភាពជាគោលការណ៏លើះ ទី១ វិធីសាស្ត្រចូលរួម (ក្រុមការងារអន្តរក្រសួង)។ទី២ វិធីសាស្ត្ររៀបចំបង្កើតយុទ្ធសាស្ត្រ និងផែនការសកម្មភាពបរិស្ថានជាតិ។ ទី៣ ចំណុចសំខាន់ៗ ដែលនឹងដាក់បញ្ចូលក្នុងឯកសារយុទ្ធសាស្ត្រ និងផែនការសកម្មភាពបរិស្ថានជាតិ។ ទី៤ ផែនការការងារ(ភារកិច្ច និងការទទួលខុសត្រូវរបស់អ្នកពាក់ព័ន្ធ) និងទី៥ បណ្តាញទំនាក់ទំនង។ | | **ឯកឧត្តម ស៊្រុន ដារិទ្ធ**<br>ទីប្រឹក្សាក្រសួងបរិស្ថាន |
| ១២.២០-១៣.៣០ | សម្រាកអាហារថ្ងៃត្រង់ | | |
| **សម័យប្រជុំទី៣ះ បរិបទ និង ការកំណត់អាទិភាពយុទ្ធសាស្ត្រ និង ផែនការសកម្មភាពបរិស្ថានជាតិ** | | | |
| ១៣.៣០-១៤.០០ | បទបង្ហាញស្តីពី របកគំហើញពីការស្រាវជ្រាវលើះ ទី១ បរិស្ថាន សេដ្ឋកិច្ច និង សង្គម។ ទី២ ការវិភាគ និន្នាការ និងស្ថានភាពធនធានធម្មជាតិ និងបរិស្ថាន។ ទី៣ ការប្រមូលព័ត៌មានដែលមានស្រាប់អំពី បណ្តាផែនការ នយោបាយ និងយុទ្ធសាស្ត្រពាក់ព័ន្ធនឹងបរិស្ថាននិងការអភិវឌ្ឍន៍ដោយចីរភាពនិង ជំហានបន្ទាប់ | បណ្ឌិត Sokhem Pech ប្រធានក្រុម ការងារគម្រោងនិងជាអ្នកឯកទេសនយោបាយបរិស្ថានអន្តរជាតិ និងការធ្វើផែនការ | **ឯកឧត្តម ខៀវ បូរិន**<br>ជំនួយការក្រសួងបរិស្ថាន |

| | | | |
|---|---|---|---|
| ១៤.០០-១៤.៥០ | សម្របសម្រួលកិច្ចពិភាក្សារួមដើម្បីៈ<br>• ស្វែងរកការឯកភាពលើការកំណត់ទស្សនៈវិស័យ ក្របខ័ណ្ឌធ្វើផែនការ និងការកំណត់អាទិភាពយុទ្ធសាស្ត្រ និងផែនការសកម្មភាពបរិស្ថានជាតិ<br>• ប្រមូលយកមតិយោបល់លើៈទី១ ការសិក្សាស្រាវជ្រាវបឋម។ ទី២ការឯកភាពលើការចូលរួមផ្តល់ព័ត៌មាន និងទិន្នន័យពីអ្នកពាក់ព័ន្ធ និងទី៣ការណែនាំលើប្រធានបទបន្ថែមដែលនឹងដាក់បញ្ចូលក្នុងឯកសារយុទ្ធសាស្ត្រ និងផែនការសកម្មភាពបរិស្ថានជាតិ។ | | |
| ១៤.៥០-១៥.១០ | សម្រាកពិសារកាហ្វេ | | |
| ១៥.១០-១៦.៣០ | សម្របសម្រួលក្រុមពិភាក្សារួមដើម្បីកំណត់វិសាលភាពរបស់យុទ្ធសាស្ត្រ និងផែនការសកម្មភាពបរិស្ថានជាតិៈ<br>• បណ្តាបញ្ហាបរិស្ថាន/ធនធានធម្មជាតិអាទិភាពដែលត្រូវដោះស្រាយ<br>• បណ្តាវិស័យអាទិភាព<br>• បណ្តាសកម្មភាពអាទិភាព និង<br>• ជម្រើសហិរញ្ញវត្ថុ | | **ឯកឧត្តម ទិន ពន្លក** អគ្គលេខាធិការ ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព |
| ១៦.៣០-១៦.៤៥ | សង្ខេបលទ្ធផលប្រជុំនិងជំហានបន្ទាប់ | លោកបណ្ឌិត លឿង កេសរោ មន្ត្រីសម្របសម្រួលគម្រោងថ្នាក់ជាតិ | |
| ១៦.៤៥-១៧.០០ | មតិបិទសិក្ខាសាលា | **ឯកឧត្តម សៅ សុភាព** | |

កំណត់សម្គាល់ៈ ក្រុមអ្នករៀបចំសូមរក្សាសិទ្ធក្នុងការកែសម្រួលកម្មវិធីក្នុងករណីចាំបាច់

## សេចក្តីបន្ថែមទី១៖ ឯកសារទស្សនៈទានស្តីពី យុទ្ធសាស្ត្រ និង ផែនការសកម្មភាព បរិស្ថានជាតិ

### ក. សាវតា

កិច្ចការពារបរិស្ថាន និងធនធានធម្មជាតិគឺសំខាន់ណាស់ នៅក្នុងប្រទេសកម្ពុជា សម្រាប់ហេតុផល ទាំងបី:

**ទី១ និរន្តរភាពបរិស្ថាន គឺជាប្រភពសំខាន់នៃ កំណើន និងការអភិវឌ្ឍន៍៖** នេះបើយោងតាម ធនាគារពិភពលោក នាពេលបច្ចុប្បន្ន បីភាគបួន នៃចំនួនប្រជាជន នៅក្នុងប្រទេសកម្ពុជា បានចូលរួមដោយផ្ទាល់នៅក្នុងវិស័យកសិកម្ម និងការនេសាទ និងពឹងអាស្រ័យ លើដី ព្រៃឈើ និង ទឹក សម្រាប់ចិញ្ចឹមជីវិត ប្រចាំថ្ងៃរបស់ពួកគេ។ កសិកម្ម និង ព្រៃឈើ ចូលរួមចំណែក ជាង៣០ភាគរយ នៃGDP របស់ប្រទេសនេះ។ វិស័យទេសចរណ៍ ដែលបានផ្អែកលើទុនបម្រុងធម្មជាតិ និង វប្បធម៌ រួមចំណែកយ៉ាងសំខាន់ផងដែរ ដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ច តាមរយៈការនាំមកនូវឱកាសការងារ និងប្រាក់ចំណូលពីបរទេស។ ការពឹងផ្អែកលើវិស័យឧស្សាហកម្មទាំងនេះ មានន័យថា ការគ្រប់គ្រងធនធានធម្មជាតិ ប្រកបដោយនិរន្តរភាព និង ទិដ្ឋភាពផ្សេងទៀត នៃបរិស្ថាន មានសារៈសំខាន់ដើម្បីបង្កើតលក្ខខណ្ឌ ដែលអនុញ្ញាតឱ្យមានកំណើនសេដ្ឋកិច្ច និង កាត់បន្ថយភាពក្រីក្រ នៅក្នុងប្រទេសកម្ពុជា សម្រាប់ថ្ងៃនេះ និង អនាគត។

**ទី២ ស្ថានភាពបច្ចុប្បន្ន នៃបរិស្ថាន ស្ថិតនៅក្រោមការគំរាមកំហែង៖** ការសិក្សាជាច្រើន ដែលពិនិត្យឡើងវិញ អំពីស្ថានភាពបច្ចុប្បន្ននៃបរិស្ថាន និងធនធានធម្មជាតិ បានបង្ហាញថា ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ សម្បទានដីសេដ្ឋកិច្ច ការកាប់ឈើខុសច្បាប់ និង ការរុករករ៉ែ ជាមូលដ្ឋានសំខាន់មួយចំនួន ដែលធ្វើឱ្យ ដីមានសំណឹក ការថយចុះព្រៃឈើ និងការបំពុលខ្យល់។ ការធ្វើឱ្យខូច គុណភាពនិងបរិមាណបរិស្ថាន បាននាំឱ្យមានផលប៉ះពាល់អវិជ្ជមាន ឧទាហរណ៍ ទៅលើផលិតភាពកសិកម្ម គ្រោះថ្នាក់ពីការប្រែប្រួលអាកាសធាតុ និងការកើនឡើងបញ្ហាសុខភាព ទាំងអស់នេះ បាននាំឱ្យមាន ផលប៉ះពាល់ សេដ្ឋកិច្ចនិង សង្គមកិច្ច។

**ទី៣ កំណើននាពេលអនាគត ត្រូវការការផ្គត់ផ្គង់ ប្រកបដោយនិរន្តរភាព នៃបរិស្ថាន និង ធនធានធម្មជាតិ៖** ជាមួយនឹងកំណើននៃ ១)ចំនួនប្រជាជន ២)ការផ្លាស់ប្តូរនៅក្នុងការប្រើប្រាស់ ៣) ទំនាក់ទំនងពាណិជ្ជកម្ម ជាមួយនឹងទីផ្សារក្នុងតំបន់ និង អន្តរជាតិ និង៤)ការព្យាករណ៍ការប្រែប្រួលអាកាសធាតុ ទាំងអស់នេះនឹងនាំឱ្យមានការប្រកួតប្រជែងច្រើន លើធនធានទឹក ដី និងខ្យល់បរិសុទ្ធ ដែលបញ្ហាទាំងនេះ នឹងត្រូវបានគេមើលឃើញ នៅក្នុងប្រទេសកម្ពុជា។ ការគ្រប់គ្រង ការវិនិយោគ និងការបង្កើនប្រសិទ្ធិភាពនៃការប្រើប្រាស់ធនធានទាំងនេះគឺ សំខាន់ណាស់ក្នុងការបំពេញតម្រូវការកំណើន នាពេលអនាគត នៅក្នុងប្រទេសកម្ពុជា។

សារៈសំខាន់នៃបរិស្ថាន និងនិរន្តរភាព ធនធានធម្មជាតិ ត្រូវបានទទួលស្គាល់ដោយ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។ "**យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣**" និង "**របៀបវារៈគោលនយោបាយសង្គមសេដ្ឋកិច្ច**" នៃ "**កម្មវិធីនយោបាយ**" ឆ្នាំ 2014-2018 របស់រាជរដ្ឋាភិបាលកម្ពុជា បញ្ជាក់ជាថ្មីនូវ បេសកកម្ម របស់

រដ្ឋាភិបាលនិង ការប្តេជ្ញាចិត្តបន្តទៀតដើម្បីការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព និងការកាត់បន្ថយភាពក្រីក្រ ក្នុងគោលបំណងដើម្បីឆ្លើយតបទៅនឹងសេចក្តីប្រាថ្នារបស់ប្រជាជន និងបរិបទ កំពុងរីកចម្រើន នៃការអភិវឌ្ឍន៍ ជាតិនិង អន្តរជាតិ (RSIII, កថាខ័ណ្ឌ៤ ទំព័រទី៤)។ ការប្តេជ្ញាចិត្តបញ្ជាបនូវ ១) និរន្តភាពបរិស្ថាន ២) ការ អភិវឌ្ឍន៍បញ្ចូលគ្នា និងមានតុល្យភាព ៣)ការប្រែប្រួលអាកាសធាតុ ៤)ការអភិវឌ្ឍន៍បៃតង ៥) ការកាត់បន្ថយ ហានិយភ័យមហន្តរាយ ក្នុងក្របខ័ណ្ឌអភិវឌ្ឍន៍ប្រទេស បានបង្ហាញឱ្យឃើញតាមរយៈការបង្កើតនូវក្រុមប្រឹក្សា ជាតិអភិវឌ្ឍន៍ដោយចីរភាព ដោយការដាក់បញ្ចូលគណៈកម្មាធិការជាតិ ស្តីពីការប្រែប្រួលអាកាសធាតុ និងក្រុម ប្រឹក្សាជាតិសម្រាប់ការអភិវឌ្ឍន៍បៃតង នាថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៥។ ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយ ចីរភាព មានសមាសភាពតំណាងជាន់ខ្ពស់ មកពីក្រសួងចំនួន ២០ ដែលមាន **សម្តេចនាយករដ្ឋមន្ត្រី** ជា ប្រធានកិត្តិយស និង រដ្ឋមន្ត្រីក្រសួងបរិស្ថាន ជាប្រធាន។ ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ត្រូវបានគាំទ្រ ដោយអគ្គលេខាធិការដ្ឋាន ដែលមានទីតាំងស្ថិតនៅក្នុងក្រសួងបរិស្ថាន (MOE, 2015)។

ក្រសួងបរិស្ថានបានធ្វើកំណែទម្រង់រចនាសម្ព័ន្ធថ្មីរបស់ខ្លួននិង បានបង្កើនកិច្ចសហប្រតិបត្តិការជាមួយ ក្រសួង និងស្ថាប័នពាក់ព័ន្ធក្នុងគោលបំណងជានា ឱ្យមានប្រសិទ្ធិភាព និងការទទួលខុសត្រូវលើតួនាទីរបស់ ពួកគេ ក្នុងកិច្ចការពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ និងការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព(MOE, 2015)។

## ខ. គោលបំណង

ការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលតែម្យ៉ាង នឹងមិនទទួលបានចីរភាពបរិស្ថានទេ ការប្តេជ្ញាចិត្តនេះតម្រូវ ឱ្យមានសំណុំច្បាស់លាស់នៃ ១)វិធានការច្បាប់ និង បទប្បញ្ញត្តិ និង ២)សកម្មភាពគោលនយោបាយនិងការ វិនិយោគ ដើម្បីដឹកនាំប្រទេសកម្ពុជាឈានទៅរក ការរក្សាបាន ការកែលម្អបរិស្ថាន និង ធនធានធម្មជាតិ របស់ ខ្លួន។ នេះគឺជា គោលបំណងចម្បងនៃ "យុទ្ធសាស្ត្រ និងផែនការសកម្មភាពបរិស្ថានជាតិ"។ តម្រូវឱ្យមានក្រោម ច្បាប់ ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ នៅក្នុងប្រទេសកម្ពុជា "យុទ្ធសាស្ត្រ និងផែន ការសកម្មភាពបរិស្ថានជាតិ" មានគោលបំណង កំណត់អត្តសញ្ញាណ៖ ១)យន្តការគោលនយោបាយអាទិភាព ២) ឧបករណ៍ និង៣)ជម្រើសនៃការផ្តល់ហិរញ្ញប្បទាន ក្នុងកិច្ចការពារ និងការវិនិយោគ ក្នុងវិស័យធនធាន ទាំងនេះ ក្នុងគ្រប់វិស័យ សេដ្ឋកិច្ច និង សង្គម នៅក្នុងប្រទេសកម្ពុជា។ ដោយសារតែពហុវិស័យនៃ ការគ្រប់គ្រង បរិស្ថាន "យុទ្ធសាស្ត្រ និងផែនការសកម្មភាពបរិស្ថានជាតិ"គឺមិនមែនជាយុទ្ធសាស្ត្រផ្តោតចំពោះជាពិសេស សម្រាប់ក្រសួងបរិស្ថាននោះទេ ប៉ុន្តែសម្រាប់ក្រសួង-ស្ថាប័នរដ្ឋាភិបាលទាំងអស់ ព្រមទាំង វិស័យឯកជន សង្គម ស៊ីវិល និងដៃគូអភិវឌ្ឍន៍ ក្នុងការដាក់បញ្ចូលបញ្ហាបរិស្ថាន ទៅក្នុងគោលនយោបាយ សេដ្ឋកិច្ច និងការវិនិយោគ នៅថ្នាក់ជាតិនិង ថ្នាក់ក្រោមជាតិ។ "យុទ្ធសាស្ត្រនិង ផែនការសកម្មភាពបរិស្ថានជាតិ"នឹងគ្របដណ្តប់រយៈពេល ឆ្នាំ២០១៦ដល់ឆ្នាំ ២០២៣ ស្របនឹងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងវដ្តផែនការជាតិផ្សេងទៀត។ ដំណើរការរៀបចំបង្កើត "យុទ្ធសាស្ត្រ និង ផែនការសកម្មភាពបរិស្ថានជាតិ" បានចាប់ផ្តើម នៅខែកញ្ញា ឆ្នាំ

២០១៥ ហើយឯកសារចុងក្រោយនឹងត្រូវត្រួតពិនិត្យ ដោយក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព មុនដាក់ជូនរាជរដ្ឋាភិបាលពិនិត្យ និង អនុម័តជាផ្លូវការ មុនដំណាច់ឆ្នាំ២០១៦។

ក្នុងគោលបំណងផ្តល់នូវអនុសាសន៍ដែលជាសកម្មភាព ជូនដល់ទីភ្នាក់ងារ និងភាគីពាក់ព័ន្ធនៅក្នុងប្រទេសកម្ពុជា "យុទ្ធសាស្ត្រ និងផែនការសកម្មភាពបរិស្ថានជាតិ"នឹង៖

(i) កំណត់ការរួមចំណែកនៃ បរិស្ថាន និងធនធានធម្មជាតិ ដល់កំណើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ - ធ្វើឱ្យមានការវិនិយោគលើបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ។

(ii) ពិនិត្យឡើងវិញ ស្ថានភាពបរិស្ថាន និង ធនធានធម្មជាតិ នាពេលបច្ចុប្បន្ននៅក្នុងប្រទេសកម្ពុជា។

(iii) វិភាគសកម្មភាពដែលនាំឱ្យមានការប្រែប្រួលបរិស្ថាន និង ធនធានធម្មជាតិ ក្នុងមួយទសវត្សរ៍កន្លងមកនេះ។

(iv) ពិនិត្យស្ថានភាពនៃការអនុវត្តន៍យុទ្ធសាស្ត្រ ដែលមានស្រាប់ស្តីពី បរិស្ថាន ការអភិវឌ្ឍន៍បៃតង និងការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព នៅថ្នាក់ជាតិ និង នៅថ្នាក់ក្រោមជាតិ។ កំណត់ បញ្ហាប្រឈម និងកត់ត្រាមេរៀនទទួលបាន ពីការអនុវត្តយុទ្ធសាស្ត្រទាំងនោះ។

(v) កំណត់ និង ផ្តល់អាទិភាព យន្តការគោលនយោបាយ និង ឧបករណ៍ ព្រមទាំង ជម្រើសក្នុងការផ្តល់ហិរញ្ញប្បទានសម្រាប់ការវិនិយោគលើគម្រោងបរិស្ថាន និងគម្រោងបញ្ជ្រាបបរិស្ថាន ទៅក្នុងវិស័យសេដ្ឋកិច្ច និងសង្គមសំខាន់ៗ (ឧ. ការអភិវឌ្ឍន៍វិស័យកសិកម្ម និង វិស័យទេសចរណ៍ប្រកបដោយនិរន្តរភាព) នៅក្នុងរយៈពេលខ្លី និង វែង។

(vi) កំណត់តួនាទីរបស់ភាគីពាក់ព័ន្ធនានា ក្នុងការអនុវត្តន៍យុទ្ធសាស្ត្រ និង ផែនការសកម្មភាពបរិស្ថានជាតិ

ជាមួយការកសាងបន្ថែម ទៅលើដំណើរការគោលនយោបាយដែលមានស្រាប់ នៅក្នុងប្រទេសកម្ពុជា "យុទ្ធសាស្ត្រ និង ផែនការសកម្មភាពបរិស្ថានជាតិ" នឹងមាន៖

(i) **ការបង្កើតឱ្យមានករណីផ្នែកសេដ្ឋកិច្ច និងសង្គម អំពីសារៈសំខាន់នៃ និរន្តរភាពបរិស្ថាន៖** នៅក្នុងគោលបំណង ដើម្បីទទួលបាននូវការចាប់អារម្មណ៍ពីស្ថាប័នហិរញ្ញវត្ថុ និងផែនការព្រមទាំងវិស័យសេដ្ឋកិច្ចសំខាន់ៗ។

(ii) **ការលើកកម្ពស់បន្ថែមទៀតនូវការបញ្ជ្រាបបរិស្ថាននៅក្នុងវិស័យ និងនៅថ្នាក់ក្រោមជាតិ៖** ដោយប្រើប្រាស់គោលដៅអភិវឌ្ឍន៍ដោយចីរភាព ជាផ្លូវថ្មីសម្រាប់ការសម្លឹងមើលជម្រើសការបញ្ជ្រាប។

(iii) **ការបង្កើតភាពជាម្ចាស់ សម្រាប់ភាគីពាក់ព័ន្ធសំខាន់ៗ៖** រៀបចំដំណើរការដាក់បញ្ចូល នៃការចូលរួមរបស់អ្នកពាក់ព័ន្ធពីថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ នៅដំណាក់កាលដំបូង និង នៅគ្រប់ការសម្រេចចិត្ត និងដោះស្រាយកង្វល់ បញ្ហានិងការប្រឈមនៃវិស័យពាក់ព័ន្ធ និងអនុម័តយន្តការលើកទឹកចិត្តនានា។

(iv) **កំណត់គោលដៅ៖** ការកំណត់គោលដៅមិនគួរផ្តោតតែលើបរិស្ថានប៉ុណ្ណោះទេ តែលើគោលដៅវិស័យផ្សេងទៀត ឧទាហរណ៍ កាត់បន្ថយ x ភាគរយ នៃការបំពុលខ្យល់ ដើម្បីជៀសវាងចំនួន y នៃការស្លាប់របស់មនុស្ស ដែលបង្កឡើងដោយជំងឺផ្លូវដង្ហើម ឬ បង្កើន z ភាគរយ នៃការផ្គត់ផ្គង់ទឹកស្អាតដោយនិរន្តរភាព ដើម្បីធានាបាននូវអត្រានគរូបនីយកម្មចង់បាន។

(v) **ផ្តល់អាទិភាពដល់ គោលនយោបាយ បទប្បញ្ញត្តិ វិធានការសេដ្ឋកិច្ច និង សារពើពន្ធ ដែលមានស្រាប់៖** នេះជាការសំខាន់ ដើម្បីជួយជៀសវាង "វិធានការ អស់កម្លាំង measures fatigue" និង ធានាឱ្យបាន

នូវការអនុវត្តន៍ជាក់ស្តែង។ សំណុំលក្ខណៈវិនិច្ឆ័យមួយ នឹងត្រូវបានណែនាំដើម្បីផ្តល់អាទិភាពឱ្យវិធានការទាំងនេះ។

(vi) **ការកំណត់នូវវិធានការជាក់ស្តែង៖** ជាជាងការរាយបញ្ជីឈ្មោះសកម្មភាពធំៗដូចជាការរៀបចំបង្កើតយុទ្ធសាស្ត្រគ្រប់គ្រងសហគមន៍ព្រៃឈើ "យុទ្ធសាស្ត្រនិងផែនការសកម្មភាពបរិស្ថានជាតិ" ផ្តោតលើការធ្វើការងារជាមួយភាគីពាក់ព័ន្ធ ដើម្បីកំណត់ជំហាននីមួយៗជាក់លាក់ ក្នុងការសម្រេចបាននូវការគ្រប់គ្រងសហគមន៍ព្រៃឈើប្រកបដោយនិរន្តរភាព។

(vii) **រៀនសូត្រពីបទពិសោធន៍របស់ប្រទេសដទៃទៀត៖** ក្រុមការងាររៀបចំបង្កើត "យុទ្ធសាស្ត្រ និង ផែនការសកម្មភាពបរិស្ថានជាតិ"នឹងពិនិត្យបទពិសោធន៍ និងមេរៀន ពីបណ្តាប្រទេសកំពុងអភិវឌ្ឍន៍នានា ក្នុងការណែនាំនូវវិធានការគោលនយោបាយ និងការទទួលយកនូវជម្រើសហិរញ្ញវត្ថុ ដើម្បីសម្រេចបាននូវការអភិវឌ្ឍន៍ ប្រកបដោយនិរន្តរភាព។

ការរៀបចំក្រមបរិស្ថានជាតិ ដើរស្របគ្នានឹងកសាងយុទ្ធសាស្ត្រ និង ផែនការសកម្មភាពបរិស្ថានជាតិជានានូវបង្កើតគោលការណ៍ និង ក្របខ័ណ្ឌច្បាប់រួមមួយ ឆ្ពោះទៅសម្រេចគោលដៅគ្រប់គ្រង និង អភិវឌ្ឍន៍ធនធានធម្មជាតិប្រកបដោយចីរភាពក្នុងព្រះរាជាណាចក្រកម្ពុជា។ ជាមួយនឹងភាពបំពេញបន្ថែមគ្នា ក្រមបរិស្ថានផ្តោតជាចម្បងលើទិដ្ឋភាពច្បាប់គ្រប់គ្រងបរិស្ថាន និងធនធានធម្មជាតិ ចំណែកឯយុទ្ធសាស្ត្រ និងផែនការសកម្មភាពបរិស្ថានជាតិវិញ គឺផ្តោតទៅលើបញ្ហាគោលនយោបាយ និងហិរញ្ញវត្ថុ។ បញ្ហាសំខាន់ៗជាច្រើននឹងត្រូវលើកយកមកពិនិត្យ និងវិភាគ ក្នុងដំណើរការរៀបចំកសាងឯកសារទាំងពីរនេះ។

## គ. សេចក្តីព្រាងមាតិកា

ផែនការសកម្មភាពបរិស្ថានជាតិនឹងកសាងបន្ថែម ទៅលើឯកសារគោលនយោបាយដែលមានស្រាប់នៅថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ ជាច្រើន រួមមាន៖

១) ផែនការយុទ្ធសាស្ត្រជាតិស្តីពី ការអភិវឌ្ឍន៍បៃតង (២០១៣-២០៣០)

២) ផែនការយុទ្ធសាស្ត្រជាតិប្រែប្រួលអាកាសធាតុ (២០១៤-២០២៣)

៣) យុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិប្រកបដោយចីរភាព

៤) ផែនការយុទ្ធសាស្ត្រ អភិវឌ្ឍន៍ជាតិ

"យុទ្ធសាស្ត្រ និងផែនការសកម្មភាពបរិស្ថានជាតិ"នេះនឹងត្រូវបានរៀបចំឡើងជា៦ជំពូក (អាស្រ័យលើការពិគ្រោះយោបល់បន្ថែមទៀត)៖

(i) **ជំពូកទី១៖** សេចក្តីផ្តើម។ ជំពូកនេះ នឹងបង្ហាញទិដ្ឋភាពទូទៅនៃ សេដ្ឋកិច្ច សង្គម និងការអភិវឌ្ឍន៍ នៅក្នុងប្រទេសកម្ពុជា។

(ii) **ជំពូកទី២៖** ការយល់ដឹងពីការចូលរួមចំណែកបរិស្ថាន និងធនធានធម្មជាតិសម្រាប់កំណើន និងការអភិវឌ្ឍន៍(តម្រូវការ និងការផ្គត់ផ្គង់ធនធានធម្មជាតិ)។ ជំពូកនេះ នឹងពិនិត្យមើលផលប្រយោជន៍ ផ្នែកសេដ្ឋកិច្ចនិងសង្គមនៃការគ្រប់គ្រងបរិស្ថានប្រកបដោយនិរន្តរភាព សម្រាប់ការរីកលូតលាស់ ភាពក្រីក្រ

និងសង្គម។ គ្រប់ទីកន្លែងដែលអាចធ្វើទៅបាន ស្ថិតិ ភស្តុតាងសេដ្ឋកិច្ច និង ករណីសិក្សានានា នឹងត្រូវបានប្រមូល ដើម្បីបង្ហាញពីករណីសេដ្ឋកិច្ច និងសង្គមនៃការគ្រប់គ្រងប្រកបដោយនិរន្តរភាពនៃបរិស្ថាន និងធនធានធម្មជាតិ។

(iii) **ជំពូកទី ៣៖** ការវិភាគស្ថានភាព។ ជំពូកនេះ នឹងត្រូវបានបែងចែកជាពីរផ្នែក៖

- ទិដ្ឋភាពទូទៅនៃស្ថានភាព និង និន្នាការនៃធនធានធម្មជាតិសំខាន់ៗ នៅក្នុងប្រទេស កម្ពុជានាពេលបច្ចុប្បន្ន ឧទាហរណ៍ ព្រៃឈើ ជីវៈចម្រុះ ទឹក និង ដីកសិកម្ម។ ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុលើធនធានធម្មជាតិទាំងនេះនឹងត្រូវបានពិនិត្យមើលក្នុងជំពូកនេះផងដែរ។
- ទាញយកយុទ្ធសាស្ត្រ គោលនយោបាយ និងកម្មវិធីចម្បងៗដែលមានស្រាប់ លើការអភិវឌ្ឍន៍ប្រកបដោយចីរភាព ការអភិវឌ្ឍន៍បៃតង និងការគ្រប់គ្រងបរិស្ថាន។ កំណត់ស្ថានភាពនៃការអនុវត្តន៍ បញ្ហាប្រឈម និង មេរៀនរបស់យុទ្ធសាស្ត្រ គោលនយោបាយ និងកម្មវិធីទាំងនោះ។ ការវិភាគអ្នកពាក់ព័ន្ធក៏នឹងត្រូវធ្វើឡើងនៅក្នុងជំពូកនេះដែរ ដើម្បីបង្ហាញពី តួនាទី និងការទទួលខុសត្រូវ នៅក្នុងរដ្ឋាភិបាលបង្កើតឡើងបច្ចុប្បន្ន ក្នុងការគ្រប់គ្រងបរិស្ថាននិងធនធានធម្មជាតិ។

(iv) **ជំពូកទី៤៖** របៀបវារៈសម្រាប់សកម្មភាព ដើម្បីសម្រេចបាននិរន្តរភាពបរិស្ថាន សម្រាប់កំណើន និងការអភិវឌ្ឍន៍រយៈពេលវែង។ ជំពូកនេះ នឹងកំណត់សំណុំនៃ គោលដៅផ្នែកបរិស្ថានអន្តរវិស័យមួយ និងបង្ហាញវិធានការគោលនយោបាយ ជម្រើសការផ្តល់ហិរញ្ញប្បទាន និងផែនការអភិវឌ្ឍន៍សមត្ថភាពដើម្បីជួយឱ្យសម្រេចបាននូវគោលដៅទាំងនេះ។ "យុទ្ធសាស្ត្រ និង ផែនការសកម្មភាពបរិស្ថានជាតិ" នឹងផ្តោតជាសំខាន់លើ វិស័យសេដ្ឋកិច្ចមួយចំនួន ដែលមានសារៈសំខាន់សេដ្ឋកិច្ចខ្លាំង ដូចជា (ត្រូវពិគ្រោះយោបល់បន្ថែមទៀត)៖

- គោលដៅ និងសកម្មភាព ដើម្បីសម្រេចបាននូវ **ការអនុវត្តន៍វិស័យកសិកម្ម ប្រកបដោយនិរន្តរភាព**
- គោលដៅ និងសកម្មភាព ដើម្បីសម្រេចបាននូវ **ការអនុវត្តន៍វិស័យជលផល ប្រកបដោយនិរន្តរភាព**
- គោលដៅ និងសកម្មភាព ដើម្បីសម្រេចបាននូវ**ការអភិវឌ្ឍន៍វិស័យទេសចរណ៍ប្រកបដោយនិរន្តរភាព**
- គោលដៅ និងសកម្មភាព ដើម្បីសម្រេចបាននូវ **ការអភិវឌ្ឍន៍វិស័យថាមពលប្រកបដោយនិរន្តរភាព**
- គោលដៅ និងសកម្មភាព ដើម្បីសម្រេចបាននូវ**ការគ្រប់គ្រងសំណល់ ដែលមាននិរន្តរភាព**

សំណុំនៃ លក្ខណៈវិនិច្ឆ័យនឹងត្រូវបានអនុវត្តនៅទីនេះ ដើម្បីកំណត់អាទិភាពសកម្មភាពដែលនឹងត្រូវអនុវត្តនៅក្នុងរយៈពេលខ្លី មធ្យម និងរយៈពេលវែង។ សារៈសំខាន់នៃ ការគ្រប់គ្រងតំបន់ការពារ ជីវៈចម្រុះ និង ការគ្រប់គ្រងប្រព័ន្ធអេកូឡូស៊ី ការកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងវិធានការបន្សាំ និងតួនាទីរបស់បច្ចេកវិទ្យានឹងត្រូវបានយកចិត្តទុកដាក់បន្ថែម។ អនុសាសន៍ទាក់ទងនឹងវិស័យ ទាំងនេះ នឹងត្រូវបានផ្តល់។

(v) **ជំពូកទី ៥៖** ការគាំទ្រពីអន្តរជាតិ។ ជំពូកនេះ នឹងបង្ហាញជូននូវការគាំទ្រជាអន្តរជាតិ នាពេលបច្ចុប្បន្នដល់ប្រទេសកម្ពុជា ស្តីពីការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពនិង ការគ្រប់គ្រងបរិស្ថាន។ វានឹងកំណត់ឱកាសក្នុងការពង្រឹងការគាំទ្រពីអន្តរជាតិនិងទទួលបានជំនួយហិរញ្ញវត្ថុ បច្ចេកទេស និងស្ថាប័នបន្ថែម ដើម្បីអនុវត្ត "យុទ្ធសាស្ត្រ និង ផែនការសកម្មភាពបរិស្ថានជាតិ"។

(vi) **ជំពូកទី ៦៖** ទិសដៅខាងមុខ។ ជំពូកនេះ នឹងបញ្ជាក់ ពីតួនាទី របស់អ្នកពាក់ព័ន្ធនានា ក្នុងការអនុវត្តន៍អនុសាសន៍របស់ "យុទ្ធសាស្ត្រ និង ផែនការសកម្មភាពបរិស្ថានជាតិ" នៅក្នុងផែនការងាររបស់ពួកគេ។

## ឃ. ការរៀបចំការអនុវត្តន៍ និង ការចូលរួមរបស់ភាគីពាក់ព័ន្ធ

ត្រួតពិនិត្យដោយក្រសួងបរិស្ថាន "យុទ្ធសាស្ត្រ និង ផែនការសកម្មភាពបរិស្ថានជាតិ" នឹងត្រូវបាន រៀបចំបង្កើតជាឯកសារណែនាំ ដល់ក្រសួងទាំងអស់ ជាពិសេស ក្រសួងផែនការ និង ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ។ ឯកសារ"យុទ្ធសាស្ត្រ និង ផែនការសកម្មភាពបរិស្ថានជាតិ" នឹងត្រូវប្រើប្រាស់ដើម្បីបង្ហាញភាគីពាក់ ព័ន្ធទាំងអស់ពីភាពអាស្រ័យ និង ផលប៉ះពាល់របស់ពួកគេលើធនធានធម្មជាតិ ឱកាសក្នុងការ កែលម្អ ការ កសាងផែនការ ប្រតិបត្តិការ និងការអនុវត្តន៍រាល់ថ្ងៃរបស់ពួកគេ ដើម្បីសម្រេចបាននូវការអភិវឌ្ឍន៍ប្រកបដោយ ចីរភាព និងសកម្មភាពជាបន្ទាន់ (ពោលគឺ វិធានការគោលនយោបាយ ជម្រើសការផ្តល់ហិរញ្ញប្បទាន និងកម្ម វិធីជាក់លាក់) ដែលនឹងត្រូវអនុវត្តនៅក្នុងគោលបំណងដើម្បីតម្រឹមគោលដៅអភិវឌ្ឍន៍ក្រសួងរបស់ខ្លួន ឱ្យស្រប ជាមួយនឹងគោលដៅអភិវឌ្ឍន៍ដោយនិរន្តរភាពរបស់ប្រទេស។

ហេតុដូច្នេះហើយបានជា ក្រុមការងារចំពោះកិច្ចអន្តរក្រសួង នឹងត្រូវបង្កើតឡើង នៅក្រោមការសម្រប សម្រួលរបស់ក្រសួងបរិស្ថាននិង ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ត្រូវមានសមាសភាព តំណាងមកពី ក្រសួងពាក់ព័ន្ធនៅក្នុងប្រទេសកម្ពុជា ដើម្បីជានាក្នុងការផ្តល់នូវធាតុចូល និងណែនាំដំណើរការរៀបចំបង្កើត។ តំណាងមកពីអង្គការសង្គមស៊ីវិល វិស័យឯកជន និងដៃគូអភិវឌ្ឍន៍នឹងត្រូវបានអញ្ជើញ ឱ្យចូលរួមនៅក្នុងការ ពិគ្រោះយោបល់ ក្នុងអំឡុងពេលរៀបចំបង្កើត "យុទ្ធសាស្ត្រ និង ផែនការសកម្មភាពបរិស្ថានជាតិ" ដើម្បីផ្តល់នូវ ធាតុចូល និងមតិយោបល់លើទិន្នន័យ ការវិភាគ និងសេចក្តីព្រាងរបាយការណ៍។

ស្នើដោយក្រសួងបរិស្ថាន និងបានគាំទ្រដោយ GMS CEP របស់ធនាគារអភិវឌ្ឍន៍អាស៊ី ការរៀបចំ បង្កើត "យុទ្ធសាស្ត្រ និង ផែនការសកម្មភាពបរិស្ថានជាតិ" នឹងត្រូវបានអនុវត្តដោយក្រុមអ្នកជំនាញការជាតិ និងអន្តរជាតិមួយ។ ក្រុមប្រឹក្សានេះនឹង ធ្វើការយ៉ាងជិតស្និទ្ធជាមួយ ខុទ្ទកាល័យ របស់ឯកឧត្តមរដ្ឋមន្ត្រីក្រសួងប រិស្ថាននិង ក្រុមការងារកិច្ចសហការ ការធ្វើផែនការ និង ការកំណត់ថវិកា លើការសម្របសម្រួលសកម្មភាព ការ រៀបចំសិក្ខាសាលា និងដាក់បញ្ចូលក្រុមការងារកិច្ចសហការ ការធ្វើផែនការ និង ការកំណត់ថវិកា នៅក្នុង សកម្មភាពអភិវឌ្ឍន៍សមត្ថភាព។

## ច. វិធីសាស្ត្រ ដែលបានស្នើឡើង

"យុទ្ធសាស្ត្រនិងផែនការសកម្មភាពបរិស្ថានជាតិ"នឹងត្រូវបានរៀបចំបង្កើតដោយផ្អែកលើវិធីសាស្ត្រ ជាដំណាក់កាល និងរួមបញ្ចូលគ្នាមួយ ដែលរួមមានដំណើរការប្រមូលទិន្នន័យ សិក្សាបណ្ណាល័យសាស្ត្រ ការ វិភាគយ៉ាងម៉ត់ចត់ និងយន្តការពិនិត្យដែលមានប្រសិទ្ធិភាព ( រូបភាព ១)។

## រូបភាព ១ វិធីសាស្ត្រដែលបានស្នើឡើងដើម្បីរៀបចំបង្កើត "យុទ្ធសាស្ត្រ និង ផែនការសកម្មភាពបរិស្ថានជាតិ

**ការគ្រប់គ្រងចំណេះដឹង ការផ្ទេរចំណេះដឹង និង ការអភិវឌ្ឍន៍សមត្ថភាព**

### ដំណាក់កាលចាប់ផ្តើម

- រៀបចំសេចក្តីព្រាងឯកសារទស្សនៈទាន សារតានៃការស្រាវជ្រាវ ធ្វើការសិក្សាបណ្ណាល័យសាស្ត្រ និង រៀបចំយុទ្ធសាស្ត្រទំនាក់ទំនង។
- សិក្ខាសាលាចាប់ផ្តើម (ការពិគ្រោះយោបល់លើកទី១) - វិធីសាស្ត្រ ដំណើរការ ផែនការការងារ កាលវិភាគបុគ្គលិក និងការរកឃើញលើគោនយោបាយ និង ផែនការ ស្ថាប័ន និង ការវិភាគស្ថានភាព នៃស្ថានភាព និង និន្នាការ។
- ប្រាស្រ័យទាក់ទងជាមួយ ក្រសួងបរិស្ថាន ក្រុមការងារចំពោះកិច្ច និង ក្រុមការងារកិច្ចសហការ ការធ្វើផែនការ និងការកំណត់ថវិកា។

### ការប្រមូលទិន្នន័យ និង ការវិភាគ

- រៀបចំកិច្ចសម្ភាសន៍អ្នកជំនាញ និងភាគីពាក់ព័ន្ធ ស្តីពីបញ្ហា ឬសគល់នៃបញ្ហា បញ្ហាប្រឈម និងគោលនយោបាយឆ្លើយតប។
- រៀបចំបង្កើតវិធីសាស្ត្រមួយ និង ម៉ាទ្រីសមួយសម្រាប់ការបញ្ជ្រាប ការឆ្លើយតប និង ការផ្តល់មូលនិធិ ។
- ការពិគ្រោះយោបល់ លើកទី២ ស្តីពី លទ្ធផលនៃការពិនិត្យបញ្ហាអាទិភាពដំបូង និង ការរៀបចំយុទ្ធសាស្ត្រ និង ផែនការសកម្មភាពនេះ។

### ដំណើរការរៀបចំសេចក្តីព្រាង និងធ្វើឱ្យមានសុពលភាព

- សរសេរសេចក្តីព្រាងNESAP ដោយធាតុចូលពីក្រុមការងារ
- សិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ លើកទី ៣ ដើម្បីពិនិត្យឡើងវិញ លើសេចក្តីព្រាង (ធាតុចូល)
- ដោះស្រាយមតិ បញ្ចប់ និង ដាក់ឯកសារNESAPចុងក្រោយសម្រាប់ពិនិត្យ និង អនុម័ត
- កិច្ចប្រជុំលើកទី៤៖ ផ្សព្វផ្សាយសារគន្លឹះ
- ពិនិត្យ និង អនុម័ត

### ព័ត៌មានដែលត្រូវការ

- ឯកសារកម្មវិធី
- វដ្តជម្មនុញ្ញ
- ច្បាប់ពាក់ព័ន្ធ
- យុទ្ធសាស្ត្រចតុកោណ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ផែនការវិនិយោគសាធារណៈ ផែនការតាមវិស័យ និង យុទ្ធសាស្ត្រ
- សម្ភារៈ NEC
- កំស្តុតាងផ្សេងទៀត

### ទម្រង់ ការវាយតម្លៃ

- សមត្ថភាពស្ថាប័ននិងសមត្ថភាព
- សារៈសំខាន់
- ប្រសិទ្ធិភាព
- ប្រសិទ្ធផល
- ផលប៉ះពាល់
- និរន្តរភាព
- ការផ្តល់ហិរញ្ញប្បទាន

### ភាគីពាក់ព័ន្ធ

- ក្រសួងបរិស្ថាន ឧទ្ទកាល័យ និង ក្រុមការងារ
- សមាជិក NCSD
- ក្រសួងពាក់ព័ន្ធសំខាន់ៗ
- ដៃគូអភិវឌ្ឍន៍
- អង្គការសង្គមស៊ីវិល
- ស្ថាប័នស្រាវជ្រាវ

### ប្រភេទ

- ស្ថាប័នពាក់ព័ន្ធ និងអង្គការសង្គមស៊ីវិល
- បុគ្គលិកកម្មវិធី
- ដៃគូក្នុងស្រុកនិងជាតិ
- សមាជិក នៃក្រុមប្រឹក្សាភិបាល របស់គម្រោង
- តំណាងរដ្ឋាភិបាលថ្នាក់ខេត្ត និង ស្រុក
- ក្រុមប្រឹក្សា ឃុំ និង ភូមិ

ដំណើរការនៃការកសាងNESAPនេះ ជាការហ្វឹកហ្វឺនអភិវឌ្ឍន៍សមត្ថភាព ដែលតាមរយៈនេះ ការគ្រប់គ្រង បរិស្ថាន និងសមត្ថភាពអភិបាលកិច្ច របស់ស្ថាប័ន និងបុគ្គលនឹងត្រូវកសាង និងពង្រឹង។

## ឆ. ការអនុវត្តផែនការ

សេរីនៃព្រឹត្តិការណ៍ពិគ្រោះយោបល់មួយ នឹងត្រូវបានរៀបចំ នៅចន្លោះ ខែកញ្ញា ឆ្នាំ២០១៥ និង ចុង ឆ្នាំ២០១៦ ដើម្បីប្រមូលព័ត៌មាន ពិនិត្យការវិភាគ និងផ្តល់មតិលើសេចក្តីព្រាងNESAPនេះ។ ខាងក្រោមនេះ គឺ ជាកាលវិភាគបណ្តោះអាសន្ន៖

| | |
|---|---|
| ខែកញ្ញា ឆ្នាំ២០១៥ | - បញ្ចប់ឯកសារទស្សនៈទាន NESAP<br>- បង្កើតក្រុមការងារបច្ចេកទេស<br>- ពិនិត្យឯកសារគោលនយោបាយសំខាន់ៗឡើងវិញ |
| ខែតុលា ឆ្នាំ២០១៥ | - ស្វែងរក មតិនិង កិច្ចព្រមព្រៀង នៅលើមាតិកា NESAP<br>- កំណត់អ្នកចូលរួមចំណែក លើទិន្នន័យ និងករណីសិក្សា<br>- ចុះកិច្ចសន្យាសិក្សាបន្ថែម ឬ ធ្វើការសិក្សាស្រាវជ្រាវចាំបាច់បន្ថែម ដើម្បីទទួលនូវចំណេះដឹងដែលមានស្រាប់ និងការវិភាគ |
| ខែវិច្ឆិកា – ខែធ្នូ ឆ្នាំ២០១៥ | - កិច្ចប្រជុំពីការចាប់ផ្តើម NESAP (ព្រឹត្តិការណ៍ពិគ្រោះយោបល់ លើកទី១) ដើម្បីយល់ព្រមលើ វិធីសាស្ត្រ ដំណើរការ និង ខ្លឹមសារ នៃNESAP<br>- សេចក្តីព្រាង លើកទី១ ជំពូកទី១ និងទី២<br>- បទសម្ភាសន៍ទ្វេភាគី និងការពិភាក្សា ជាក្រុមតូច ដើម្បីប្រមូលព័ត៌មាន<br>- រៀបចំយុទ្ធសាស្ត្រទំនាក់ទំនងមួយសម្រាប់ NESAP |
| ខែមករា/កុម្ភៈ ឆ្នាំ២០១៦ | - សេចក្តីព្រាង លើកទី១ ជំពូកទី៣ និងទី៤ |
| ខែមិនា ឆ្នាំ២០១៦ | - សេចក្តីព្រាង លើកទី១ ជំពូកទី៥ និងទី៦ |
| ខែមេសា - ខែឧសភា ឆ្នាំ ២០១៦ | - ពង្រឹង សេចក្តីព្រាង ទី១ នៃឯកសារ NESAPពេញលេញ<br>- ការពិនិត្យផ្ទៃក្នុងដោយក្រសួងបរិស្ថាន ដោយក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព និង ដោយ EOC លើឯកសារសេចក្តីព្រាង NESAP<br>- ពិគ្រោះយោបល់លើកទី២ ដើម្បីពិនិត្យឡើងវិញសេចក្តីព្រាង NESAP ពេញលេញ<br>- ពិគ្រោះយោបល់ជាមួយ ក្រុមការងារក្រមបរិស្ថានជាតិ ដើម្បីពិនិត្យនិង ផ្តល់មតិ |
| ខែមិថុនា - ខែ កក្កដា ឆ្នាំ ២០១៦ | - បញ្ចូលមតិ<br>- សេចក្តីព្រាង លើកទី២ នៃឯកសារ NESAP ពេញលេញ<br>- ព្រឹត្តិការណ៍ពិគ្រោះយោបល់ លើកទី ៣ |
| ខែសីហា - ខែកញ្ញា ឆ្នាំ២០១៦ | - បញ្ចូលមតិ ធ្វើការកែសម្រួល និង NESAP ចុងក្រោយ |
| ខែតុលា ២០១៦ | - ព្រឹត្តិការណ៍ ពិគ្រោះយោបល់ លើកទី៤ ដើម្បីផ្សព្វផ្សាយសារគន្លឹះពី NESAP |
| ខែវិច្ឆិកា ២០១៦ | - NESAP ទទួលការត្រួតពិនិត្យ ដោយក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព |
| ខែធ្នូ ឆ្នាំ២០១៦ | - NESAP ទទួលបានការអនុម័តជាផ្លូវការពីរាជរដ្ឋាភិបាលកម្ពុជា |